**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និង នេសាទ

លេខ ៣៣៩ សសរ. កសក

# សេចក្តីសម្រេច
## ស្តីពី
## ការបង្កើតក្រុមការងារផ្សព្វផ្សាយព័ត៌មាន តាមបណ្តាញសង្គម(ហ្វេសប៊ុក)របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្តីពីការកែសម្រួលសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៣ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៧ អនក្រ.បក ចុះថ្ងៃទី០៧ ខែមេសា ឆ្នាំ២០០០ ស្តីពីការរៀបចំ និងការប្រព្រឹត្តទៅរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- បានឃើញអនុក្រឹត្យលេខ១៨៨ អនក្រ.បក ចុះថ្ងៃទី១៤ ខែវិច្ឆិកា ឆ្នាំ២០០៨ ស្តីពីការកែសម្រួលអគ្គនាយកដ្ឋាននៃក្រសួងទៅជាអគ្គលេខាធិការដ្ឋាន ការដំឡើងរដ្ឋបាលព្រៃឈើ រដ្ឋបាលជលផល ឱ្យមានថ្នាក់ស្មើអគ្គនាយកដ្ឋាន ការដំឡើងនាយកដ្ឋានក្សេត្រសាស្ត្រនិងកែលម្អដីកសិកម្ម ឱ្យទៅជាអគ្គនាយកដ្ឋានកសិកម្ម និងការកែសម្រួលអគ្គនាយកដ្ឋានចម្ការកៅស៊ូ ទៅជាអគ្គនាយកដ្ឋានកៅស៊ូ ស្ថិតក្រោមការគ្រប់គ្រងរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
- យោងតាមការចាំបាច់របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ

## សម្រេច

**ប្រការ១._**

ត្រូវបានបង្កើតក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម (ហ្វេស ប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដែលមានសមាសភាពដូចខាងក្រោមៈ

| | | | |
|---|---|---|---|
| ១.ឯកឧត្តម | **នុត ច័ន្ទសុខា** | អនុរដ្ឋលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | ប្រធាន |
| ២.ឯកឧត្តម | **ឡោ រស្មី** | អគ្គលេខាធិការក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៣.លោក | **ប្រាក់ ថាវអមិដា** | អគ្គលេខាធិការរងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | អនុប្រធាន |
| ៤.ឯកឧត្តម | **គឹម សុន** | អគ្គាធិការនៃអគ្គាធិការដ្ឋាន | សមាជិក |

អាស័យដ្ឋានលេខ ២០០ មហាវិថីព្រះនរោត្តម សង្កាត់ទន្លេបាសាក់ ខណ្ឌចំការមន រាជធានីភ្នំពេញ កម្ពុជា
N° 200 Preah Norodom Blvd., Sangkat Tonle Basak, Khan Chamkarmon, Phnom Penh, Cambodia
ទូរស័ព្ទលេខ : (០២៣) ៧២៦ ១២៨/ ៧២៦ ១២៩ ទូរសារលេខ : (៨៥៥) ២៣-២១៧ ៣២០
Phone : (023) 726 128 / 726 129, Fax : (855) 23 - 217 320

| | | | |
|---|---|---|---|
| ៥.ឯកឧត្តម | **ឆេង គឹមស៊ុន** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកប្រធានរដ្ឋបាលព្រៃឈើ | សមាជិក |
| ៦.ឯកឧត្តម | **ស្វ ខនឬទ្ធីគុណា** | ប្រតិភូរាជរដ្ឋាភិបាលទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកសិកម្ម | សមាជិក |
| ៧.ឯកឧត្តម | **អេង ជាសាន** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាប្រធាន រដ្ឋបាលជលផល | សមាជិក |
| ៨.ឯកឧត្តម | **ម៉ុល សុផា** | ប្រតិភូរាជរដ្ឋាភិបាលកម្ពុជាទទួលបន្ទុកជាអគ្គនាយក នៃអគ្គនាយកដ្ឋានកៅស៊ូ | សមាជិក |
| ៩.លោក | **សរ ចិត្រា** | អគ្គលេខាធិការរងនៃក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ១០.លោក | លោកស្រីប្រធានគ្រប់អង្គភាពក្រោមឱវាទក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | | សមាជិក |
| ១១.លោក | **ហុង ណារិត** | ប្រធានមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម | សមាជិកអចិន្ត្រៃយ៍ |
| ១២.លោក | **ភោ ម៉ួយឆៃ** | ប្រធានការិយាល័យព័ត៌មានកសិកម្ម | លេខាធិការ |
| ១៣.លោក | **ជីវ រចនា** | ប្រធានបណ្ណាល័យកសិកម្ម | លេខាធិការ |
| ១៤.លោក | **សុខ សុភាព** | ប្រធានការិយាល័យព័ត៌មានភូមិសាស្ត្រកសិកម្ម | លេខាធិការ |

**ប្រការ២._**

ក្រុមការងារផ្សព្វផ្សាយព័ត៌មានតាមបណ្តាញសង្គម (ហ្វេសប៊ុក) របស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ មានភារកិច្ចដូចខាងក្រោម៖

- ផ្សព្វផ្សាយនិងផ្តល់ព័ត៌មានអំពីគោលនយោបាយ គោលការណ៍ និងសកម្មភាពសំខាន់ៗរបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ជូនសាធារណជនទូទៅបានជ្រាបតាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក)
- បកស្រាយបំភ្លឺជូនសាធារណមតិឱ្យបានយល់ច្បាស់អំពីសភាពការណ៍វិវត្តន៍ និងបញ្ហាពាក់ព័ន្ធទៅនឹងសកម្មភាព ឬសេចក្តីសម្រេចនានារបស់ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ តាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក)
- ធ្វើការតាមដាន ស្រង់ព័ត៌មានបណ្តាញសង្គម (ហ្វេសប៊ុក) របស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា** ដែលមានពាក់ព័ន្ធនឹងក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ដើម្បីធ្វើការឆ្លើយតប និងដោះស្រាយជូនប្រជាពលរដ្ឋឱ្យបានទាន់ពេលវេលា
- ប្រធាន អនុប្រធាន និងសមាជិកក្រុមការងារ ត្រូវធ្វើការទំនាក់ទំនងគ្នាជាប់ជាប្រចាំតាមរយៈបណ្តាញសង្គម ឬបណ្តាញទំនាក់ទំនងស្របតាមការកំណត់របស់ក្រុមការងារ
- សមាជិកក្រុមការងារដែលជាប្រធានអង្គភាពជំនាញនៃក្រសួង ត្រូវទទួលខុសត្រូវនិងធានាបញ្ជូនព័ត៌មាន មតិបកស្រាយបំភ្លឺលើមតិសាធារណជនពាក់ព័ន្ធទៅនឹងជំនាញរបស់ខ្លួន ឱ្យបានទាន់ពេលវេលាតាមរយៈបណ្តាញទំនាក់ទំនងរបស់ក្រុមការងារ និងបញ្ជូនមកក្រុមលេខាធិការ ដើម្បីចាត់ចែងធ្វើសម្រង់ខ្លឹមសារផ្សព្វផ្សាយបំភ្លឺជូនសារធារណជនតាមរយៈបណ្តាញសង្គម (ហ្វេសប៊ុក) តាមការចាំបាច់
- ក្រុមការងារត្រូវប្រជុំប្រចាំខែ ឬនៅពេលវេលាចាំបាច់ណាមួយតាមការអញ្ជើញរបស់ប្រធានក្រុម ដើម្បីត្រួតពិនិត្យសកម្មភាពការងារ និងកំណត់ទិសដៅការងារដែលត្រូវអនុវត្តបន្ត។

**ប្រការ៣._**

សេចក្តីសម្រេចលេខ០១៧ សសរ.កសក ចុះថ្ងៃទី១៣ ខែមករា ឆ្នាំ២០១៦ លេខ១១៥ សសរ.កសក ចុះថ្ងៃទី១០ ខែកុម្ភៈ ឆ្នាំ២០១៦ និងសេចក្តីសម្រេចទាំងឡាយណាដែលមានខ្លឹមសារផ្ទុយនឹងសេចក្តីសម្រេចនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៤._**

អគ្គលេខាធិការ អគ្គាធិការ នាយកខុទ្ទកាល័យ ប្រធាននាយកដ្ឋានបុគ្គលិកនិងអភិវឌ្ឍន៍ធនធានមនុស្ស ប្រធាននាយកដ្ឋានផែនការនិងស្ថិតិ ប្រធាននាយកដ្ឋានគណនេយ្យ ហិរញ្ញវត្ថុ ប្រធានមជ្ឈមណ្ឌលព័ត៌មាននិងឯកសារកសិកម្ម ប្រធានអង្គភាពពាក់ព័ន្ធ និងសាមីខ្លួន ត្រូវទទួលបន្ទុកអនុវត្តសេចក្តីសម្រេចនេះតាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ, ថ្ងៃទី ១៣ ខែ មិថុនា ឆ្នាំ២០១៦

**រដ្ឋមន្ត្រី**

**ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ**

**វេង សាខុន**

**កន្លែងទទួល៖**

-ទីស្តីការគណៈរដ្ឋមន្ត្រី
-ក្រសួងមហាផ្ទៃ
-ក្រុមប្រឹក្សាស្តារ អភិវឌ្ឍន៍វិស័យកសិកម្ម និងជនបទ
-ក្រសួងមុខងារសាធារណៈ
-ក្រសួងព័ត៌មាន
"ដើម្បីជូនជ្រាប"
-ដូចប្រការ៤
"ដើម្បីអនុវត្ត"
-ឯកសារ កាលប្បវត្តិ